Landesa



# កាបូនខៀវ

## ការវាយតម្លៃសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈការពង្រឹងអាណត្តិរបស់សហគមន៍នេសាទនៅតំបន់ឆ្នេរ

**ប្រទេសកម្ពុជា**

**ករណីសិក្សា**

រក្សាសិទ្ធិ © ២០២៤

Landesa
១៤២៤ វិថីទី៤ លេខ ៤៣០,
ស៊ីអាថល
សហរដ្ឋអាមេរិក

**អ្នកនិពន្ធ៖** Juan Robalino, Sophal Sam, Rusrann Loeng

**អ្នកពិនិត្យ៖** Rachel McMonagle, Corey Creedon, Tatiana Gumucio, Christine Anderson, Ry Ravenholt

ការវាយតម្លៃនេះមិនអាចធ្វើទៅបានឡើយ បើគ្មានការគាំទ្រដ៏មានតម្លៃ និងទិន្នន័យដែលផ្តល់ដោយរដ្ឋបាលជលផលថ្នាក់ជាតិ រដ្ឋបាលខេត្តព្រះសីហនុ រដ្ឋបាលជលផលខេត្តកំពត រដ្ឋបាលជលផលខេត្តព្រះសីហនុ និងសមាជិកគណៈកម្មការនៃសហគមន៍នេសាទកោះ-គ្រឹះស្នាលក សហគមន៍នេសាទបន្ទាយប្រិយ៍ សហគមន៍នេសាទសំរុង សហគមន៍នេសាទជំពូរខ្មៅ និងសហគមន៍នេសាទបឹងរាំង ។

*ការងាររបស់ Landesa នៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា ធ្វើឡើងតាមរយៈអង្គការដៃគូក្នុងស្រុករបស់ខ្លួន៖*

*របាយការណ៍នេះត្រូវបានរៀបចំឡើង ក្រោមការឧបត្ថម្ភពីមូលនិធិ King Philanthropies*

## សេចក្តីបដិសេធ

របាយការណ៍នេះត្រូវបានរៀបចំឡើងដោយ Landesa។ របាយការណ៍នេះមានគោលបំណងតែមួយគត់ គឺផ្តល់ព័ត៌មាន និងពង្រឹងការយល់ដឹងអំពីគម្រោង ក៏ដូចជាបង្កើនការគាំទ្រដល់គម្រោង ដូច្នេះ មិនមានការបញ្ចេញមតិយោបល់ ឬសេចក្តីសន្និដ្ឋានណាមួយដែលមានបំណងបញ្ជាក់ ឬធានាលើលទ្ធផលជាក់លាក់ណាមួយនោះទេ ហើយក៏មិនគួរត្រូវបានបកស្រាយថាជាការបញ្ជាក់ ឬការធានាដូច្នេះដែរ។

Landesa មិនទទួលខុសត្រូវចំពោះកាតព្វកិច្ចណាមួយ និងមិនទទួលយកទំនួលខុសត្រូវអ្វីឡើយ ចំពោះការអនុវត្តខុស ឬការបកស្រាយខុសដោយភាគីទីបីនូវខ្លឹមសារនៃរបាយការណ៍នេះ។ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់ Landesa មិនព្យាយាមផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ សុពលភាព ឬភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានណាមួយដែលបានផ្តល់នៅក្នុងរបាយការណ៍នេះទេ។ នៅក្នុងរបាយការណ៍នេះ យើងបានបញ្ជាក់នូវប្រភពនៃព័ត៌មានដែលបានផ្តល់។ លទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះត្រូវបានបង្កើតឡើង ផ្អែកលើមូលដ្ឋានខាងលើ។

# សេចក្តីសង្ខេប

នៅក្នុងប្រទេសកម្ពុជា សហគមន៍នេសាទត្រូវបានបង្កើតឡើង ដើម្បីផ្តល់ឲ្យវិស័យផលផល និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ នូវការគ្រប់គ្រងដែលផ្តោតលើសហគមន៍ (ដូចជា ព្រៃកោងកាង ជាដើម)។ បច្ចុប្បន្ននេះ សមាជិកសហគមន៍បានក្លាយជាភ្នាក់ងារអភិរក្ស និងស្តារព្រៃកោងកាងឡើងវិញ។ ទោះបីជាសហគមន៍មានសិទ្ធិ និងសមត្ថភាពក្នុងការគ្រប់គ្រងធនធានយ៉ាងណាក៏ដោយ ការរៀបចំបែងចែកធនធាន ការរៀបចំបន្តអាណត្តិរបស់សហគមន៍នេសាទនៅខ្សោយ ហើយបានបង្កឱ្យមានបញ្ហាប្រឈមគួរឱ្យកត់សម្គាល់មួយចំនួន។ ការរៀបចំក្នុងអាណត្តិទាំងអស់នេះ រួមមានការកំណត់ព្រំប្រទល់មិនមានភាពច្បាស់លាស់ កង្វះការសម្របសម្រួល ហើយការគ្រប់គ្រង និងការការពារទៀតនោះក៏នៅមានកម្រិត ដែលធ្វើសហគមន៍មានការលំបាកក្នុងការទាញយកធនធាន និងផ្លាស់ប្តូរការប្រើប្រាស់ដីធ្លីបាន។ ដូច្នេះ ការរៀបចំទាំងនេះធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងរយៈពេលវែង និងការអភិវឌ្ឍប្រកបដោយចីរភាពនៃសហគមន៍នេសាទ។

តាមរយៈគម្រោងជីវភាព និងព្រៃកោងកាងតំបន់ឆ្នេរ និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធជាច្រើន អង្គការឡែនដេសា (Landesa) កំពុងពង្រឹងអាណត្តិដែលមានសុវត្ថិភាពរបស់សហគមន៍នេសាទ នៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ជាយន្តការដើម្បីធានានិរន្តរភាពនៃការប្រកបមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទនៅតំបន់ឆ្នេរ ការពារព្រៃកោងកាង និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ នៅក្នុងប្រទេសកម្ពុជា អង្គការ Landesa កំពុងធ្វើការតាមរយៈអង្គការដៃគូក្នុងស្រុករបស់ខ្លួន ដែលមានតំបន់គោលដៅសាកល្បងចំនួនពីរ៖ សហគមន៍នេសាទកោះគ្រឺះស្ទាលក និងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ (MFMA)។

ការពង្រឹងអាណត្តិសហគមន៍ និងសុវត្ថិភាពដែនដី និងការគ្រប់គ្រងរួមគ្នាលើធនធាន នៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរនៅកម្ពុជា គឺជាអភិក្រមជាយុទ្ធសាស្ត្រដើម្បីអភិរក្ស និងប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ និងសមុទ្រប្រកបដោយចីរភាព ដែលរួមចំណែកដោយផ្ទាល់ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ Landesa បានប៉ាន់ប្រមាណថា ការដាំព្រៃកោងកាងឡើងវិញ និងការបញ្ចៀសការបំផ្លាញព្រៃកោងកាង និងស្មៅសមុទ្រ ដោយសហគមន៍នេសាទនៅតំបន់ឆ្នេរចំនួន ៨ ក្នុងចំណោម ៤១ មានអាណត្តិសុវត្ថិភាពដែនដី និងអនុវត្តការគ្រប់គ្រងរួមគ្នាលើធនធានក្នុងសហគមន៍ អាចរួមចំណែកប្រមាណ 46,506 $tCO2_e$ ក្នុងមួយឆ្នាំ ។ កត្តានេះកាន់តែមាន

សារៈសំខាន់ នៅពេលពិចារណាលើការរួមចំណែកថ្នាក់ជាតិ (NDC) របស់កម្ពុជា ដែលបានដាក់ចេញចំណុចដៅកាត់បន្ថយការបញ្ចេញឧស្ម័នកន្លងមកពី វិស័យ ព្រៃឈើនិងការប្រើប្រាស់ដីផ្សេងទៀតឱ្យបាន ៥០% ត្រឹមឆ្នាំ ២០៣០ (ជាមធ្យម 21.54 $MtCO_2e$ ក្នុងមួយឆ្នាំ)។ ដូច្នេះការអភិរក្ស និងស្តារឡើងវិញដែលទទួលបានជោគជ័យក្រោមក្របខណ្ឌនៃការបន្តអាណត្តិដែលមានសុវត្ថិភាព និងការគ្រប់គ្រងរួមគ្នាលើធនធាន ដោយមានការគាំទ្រពីរដ្ឋាភិបាល នៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរ គឺជាឱកាសមួយ សម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រដល់ការសម្រេចគោលដៅប្រកបដោយមហិច្ឆតារបស់ប្រទេសកម្ពុជាដែលបានកំណត់ក្នុងការរួមចំណែកថ្នាក់ជាតិ (NDC)។

របាយការណ៍នេះរៀបរាប់អំពីលទ្ធផលរកឃើញនៃការវាយតម្លៃកាបូន ដែលត្រូវបានធ្វើឡើងនៅតំបន់គោលដៅសាកល្បងចំនួនពីរ ដែលគាំទ្រដល់ការពង្រីកវិសាលភាពនៃការអនុវត្តអភិក្រមផ្អែកលើអាណត្តិស្របច្បាប់ ទៅកាន់សហគមន៍នេសាទនៅតំបន់ឆ្នេរទាំងអស់ ជាសមាសភាគបន្ថែមមួយនៃភាពជាអ្នកដឹកនាំរបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយកាបូន តាមរយៈការរួមចំណែកថ្នាក់ជាតិដែលបានកំណត់ (NDC) របស់ខ្លួន។

# មាតិកា

**សេចក្ដីសង្ខេប** ........ 3
សេចក្ដីផ្ដើម ........ 6
កម្ពុជា និងសហគមន៍នេសាទ ........ 6
គម្រោងជីវភាពរស់នៅ និងព្រៃកោងកាងតំបន់ឆ្នេរ របស់ Landesa ........ 8
គោលបំណង ........ 10
**វិធីសាស្ត្រ** ........ 10
**កាបូនខៀវ និងការរួមចំណែកថ្នាក់ជាតិដែលបានកំណត់របស់កម្ពុជា** ........ 12
កាបូនខៀវនៅកម្ពុជា ........ 12
ចំណាកសម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀតក្នុង NDC របស់ កម្ពុជា ........ 13
**កាបូនខៀវនៅសហគមន៍នេសាទកោះគ្រឹះស្លាលក** ........ 15
ការវាយតម្លៃតុល្យភាពកាបូនខៀវ ........ 16
លទ្ធផលនៃតុល្យភាពកាបូនខៀវ ........ 17
**កាបូនខៀវនៅតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់** ........ 19
ការវាយតម្លៃតុល្យភាពកាបូនខៀវ ........ 20
លទ្ធផលនៃតុល្យភាពកាបូនខៀវ ........ 21
**សេចក្ដីសន្និដ្ឋាន** ........ 23
ឯកសារយោង ........ 25
ឧបសម្ព័ន្ធទី១ ........ 26




# សេចក្តីផ្តើម

## កម្ពុជា និងសហគមន៍នេសាទ

កម្ពុជា ត្រូវបានចាត់ទុកថាជាចំណុចក្តៅនៃការកាប់បំផ្លាញព្រៃកោងកាងមួយ ក្នុងចំណោមចំណុចក្តៅនានា នៅតំបន់អាស៊ីអាគ្នេយ៍ ដោយមានអត្រាបាត់បង់ព្រៃកោងកាងខ្ពស់បំផុត ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩០០ និង ២០០០ (ArcGIS, ២០២១) (Bijeesh & Ngo,២០១៩)(សូមមើលរូបភាពទី១)។ **សហគមន៍នេសាទត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងកម្មវិធីមួយ ដែលបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតា ហើយដែលបានអនុវត្តចាប់តាំងពីឆ្នាំ ២០០០មក** ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញឱ្យមានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើសហគមន៍ ក្នុងវិស័យជលផល និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ (ដូចជា ព្រៃកោងកាង ជាដើម)។ អនុវត្តដោយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការបង្កើតសហគមន៍នេសាទ មានគោលបំណងចម្បង គឺដើម្បីគ្រប់គ្រងជលផល និងធនធានពាក់ព័ន្ធ ប្រកបដោយចីរភាព និងសមធម៌ សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ។

រូបភាពទី 1. បម្រែបម្រួលសុទ្ធនៃព្រៃកោងកាងនៅកម្ពុជា (ហិកតា)។




*កំណត់សម្គាល់៖ ទំហំនៃព្រៃកោងកាងនៅកម្ពុជាបានថយចុះចំនួន ១.៩៦៣,៩ ហិកតា រវាងឆ្នាំ ១៩៩៦ និង ២០២០* (GMW, 2024)*។ ការដាំព្រៃឡើងវិញ ការហាមឃាត់ការផលិតធ្យូងខុសច្បាប់ និងការបិទស្រះវារីវប្បកម្មដែលមិនមានប្រាក់ចំណេញ គឺជាកត្តាគន្លឹះមួយចំនួនដែលគេជឿថា បានបណ្តាលឱ្យការបាត់បង់ព្រៃកោងកាងមានការថមថយ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ* (Bijeesh & Ngo, 2019)*។*

*ប្រភព៖ (GMW, 2024).*

គំរូសហគមន៍នេសាទ ផ្តល់ឱ្យសមាជិករបស់ខ្លួននូវសិទ្ធិរៀបចំ សហប្រតិបត្តិការ និង សកម្មភាពការពារការនេសាទ ហើយក្នុងពេលជាមួយគ្នានេះផងដែរ អនុញ្ញាតឱ្យសហគមន៍អាចប្រើប្រាស់ និងគ្រប់គ្រងធនធានជលផលទាំងអស់ ស្របតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងសហគមន៍នេសាទ។ ដោយហេតុថា នេះជាសិទ្ធិប្រើប្រាស់មានកម្រិត សហគមន៍នេសាទមិនមានសិទ្ធិលក់ដីណាមួយ ផ្តល់សិទ្ធិប្រើប្រាស់ទៅឱ្យអ្នកនៅក្រៅសហគមន៍ ឬសាងសង់សំណង់ណាមួយ ដោយគ្មានការអនុញ្ញាតជាមុន ពីរដ្ឋបាលជលផលឡើយ។ សហគមន៍នេសាទមិនអាចបែងចែក ឬបង្កើតកម្មសិទ្ធិឯកជនប្រភេទណាមួយនៅក្នុងតំបន់នេះទេ ហើយក៏មិនអាចចុះកិច្ចព្រមព្រៀងជាមួយបុគ្គល ឬអង្គភាពណាមួយបានដែរ (FAO, 2017)។

សព្វថ្ងៃនេះ **ទោះបីជាសមាជិកសហគមន៍នេសាទដើរតួនាទីយ៉ាងសំខាន់ ក្នុងការដាំដើមកោងកាង និងការពារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរក៏ដោយ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ កំពុងរងការគំរាមកំហែងពីអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ និងគម្រោងអភិវឌ្ឍន៍ថ្មីៗ** (Landesa, 2023)។ បើតាមធនាគារអភិវឌ្ឍន៍អាស៊ី **ជម្រកស្មៅសមុទ្រកំពុងថយចុះ ៧% ជារៀងរាល់ឆ្នាំ ខណៈដែលព្រៃកោងកាងកំពុងថយចុះចន្លោះ ៣% ទៅ ៥% ជារៀងរាល់ឆ្នាំ** ដោយគម្រោងអភិវឌ្ឍន៍តំបន់ឆ្នេរសំខាន់ៗកំពុងគំរាមកំហែងដល់តំបន់ព្រៃកោងកាង និងស្មៅសមុទ្រដ៏ធំល្វឹងល្វើយនៅកម្ពុជា (ADB, 2022)។

**ការកំណត់ព្រំប្រទល់ និងដែនសហគមន៍នេសាទមិនមានភាពច្បាស់លាស់ ការខ្វះការសម្របសម្រួលរវាងភាគីពាក់ព័ន្ធជាច្រើន និងធនធានមានកម្រិតសម្រាប់ការគ្រប់គ្រង និងការពារ បានបណ្តាលឱ្យមានសកម្មភាពខុសច្បាប់ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ការប្រកបមុខរបរចិញ្ចឹមជីវិត របស់សមាជិកសហគមន៍នេសាទ និងរារាំងការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ ប្រកបដោយប្រសិទ្ធភាព។** ក្នុងពេលជាមួយគ្នានេះ ការខ្វះការសម្របសម្រួល និងធនធានមានកម្រិត បានបង្កការលំបាកដល់ការសហការប្រកបដោយប្រសិទ្ធភាព ក្នុងការអនុវត្តការងារល្បាត និងអភិរក្សធនធានធម្មជាតិរួមគ្នា។ ការនេសាទខុសច្បាប់ និងការទាញយកធនធានព្រៃឈើ បានបង្កើតជាវដ្តមួយ ដែលធនធាននៅសល់ សម្រាប់សមាជិកសហគមន៍នេសាទ មិនគ្រប់គ្រាន់សម្រាប់ចំណាយលើការងារល្បាត ការការពារធនធាន និងការអភិវឌ្ឍគំនិតផ្តួចផ្តើមនានាឡើយ។ លើសពីនេះទៀត ការរេចរិលព្រៃកោងកាង និងការប្រែប្រួលអាកាសធាតុ ក៏បានដាក់កំហិតលើឱកាសប្រកបមុខរបរចិញ្ចឹមជីវិតរបស់សមាជិកសហគមន៍នេសាទ ជា

ពិសេសស្ត្រី។ ជារួម ឱកាសប្រកបរបរចិញ្ចឹមជីវិតមានតិចតួច ដែលបានពីការគ្រប់គ្រងព្រៃកោងកាងប្រកបដោយចីរភាព កំពុងជំរុញឱ្យក្មេងជំនាន់ក្រោយស្វែងរកឱកាសការងារក្នុងវិស័យផ្សេងទៀត (Landesa, 2023)។

## គម្រោងជីវភាពរស់នៅ និងព្រៃកោងកាងតំបន់ឆ្នេរ របស់ Landesa

Landesa តាមរយៈ**គម្រោងជីវភាពរស់នៅ និងព្រៃកោងកាងតំបន់ឆ្នេរ**[1] កំពុងពង្រឹងអាណត្តិសហគមន៍នេសាទតំបន់ឆ្នេរនៅឈូងសមុទ្របង់ហ្គាល់ (បង់ក្លាដេស និងឥណ្ឌា) និងអាស៊ីអាគ្នេយ៍ (មីយ៉ាន់ម៉ា ថៃ កម្ពុជា និងឥណ្ឌូនេស៊ី)។ គម្រោងដែលមានគោលដៅប្រកបដោយមហិច្ឆតានេះ មានគោលបំណងជានានិរន្តរភាពមុខរបរចិញ្ចឹមជីវិត ការពារព្រៃកោងកាង និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈសកម្មភាពឆ្លើយតបទៅនឹងសមភាពយេនឌ័រ និងបរិយាបន្នសង្គម (GESI) ស្របតាមបរិបទនៅក្នុងប្រទេសនីមួយៗ ។ សកម្មភាពទាំងនេះរួមមានការផ្តល់យោបល់ផ្នែកគោលនយោបាយ ការគាំទ្រផ្នែកនីតិកម្ម ការវាយតម្លៃសហគមន៍ ការធ្វើផែនទីគម្របព្រៃឈើ ព្រមទាំងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក្រោមការដឹកនាំដោយអ្នកនៅមូលដ្ឋានផ្ទាល់។

នៅកម្ពុជា **Landesa កំពុងធ្វើការតាមរយៈអង្គការដៃគូក្នុងស្រុករបស់ខ្លួន នៅទីតាំងសាកល្បងចំនួនពីរ៖** សហគមន៍នេសាទកោះគ្រឹះស្នាលក ស្ថិតនៅខេត្តកំពត និងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ (MFMA) នៅខេត្តព្រះសីហនុ។

សហគមន៍នេសាទកោះគ្រឹះស្នាលក គឺជាការបញ្ចូលគ្នារវាងសហគមន៍នេសាទលក (ទទួលស្គាល់តាំងពីឆ្នាំ ២០០៦) និងសហគមន៍នេសាទកោះគ្រឹះស្នា (ទទួលស្គាល់តាំងពីឆ្នាំ ២០១៣)។ ចាប់តាំងពីឆ្នាំ ២០១៩ មក រដ្ឋបាលជលផលខេត្តកំពត រួមជាមួយអង្គការក្រៅរដ្ឋាភិបាល បានចាប់ផ្តើមជួយសហគមន៍នេសាទកោះគ្រឹះស្នាលក រៀបចំកការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទថ្មីឡើងវិញ កំណត់ព្រំប្រទល់ថ្មីនៃសហគមន៍នេសាទដែលបានច្របាច់បញ្ចូលគ្នា និងកំណត់អត្តសញ្ញាណសមាជិកសហគមន៍នេសាទ។

ដោយឡែក តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ (MFMA) ត្រូវបានបង្កើតឡើង និងទទួលស្គាល់ជាផ្លូវការនៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២៣ (ប្រកាសលេខ ៥០៤)។ គោលបំណងចម្បងនៃការបង្កើតតំបន់គ្រប់គ្រងនេះ គឺដើម្បីគ្រប់គ្រងជលផលសមុទ្រ កែលម្អប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ លើកកម្ពស់ទេសចរណ៍ធម្មជាតិ ការពារជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងពង្រឹងភាពធន់របស់ពួកគេទៅនឹងការប្រែប្រួលអាកាសធាតុ។ សហគមន៍នេសាទទាំងប្រាំពីរ ដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ត្រូវបានបង្កើតឡើង ត្រឹមឆ្នាំ ២០០៤ និងត្រូវបានទទួលស្គាល់ ឬស្ថិតក្នុងដំណើរការនៃការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រឹមឆ្នាំ ២០១០។

[1] https://cdn.landesa.org/wp-content/uploads/Coastal-Livelihoods-and-Mangroves-Project-brochure.pdf

**ដោយសារចំណាប់អារម្មណ៍លើការអភិរក្សព្រៃកោងកាង និងការគ្រប់គ្រងធនធានប្រកបដោយចីរភាពមានការកើនឡើង ក្នុងចំណោមសហគមន៍នេសាទ និង រដ្ឋាភិបាល Landesa កំពុងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងសហការ ជាមួយភាគីពាក់ព័ន្ធ ដើម្បីពង្រឹងសិទ្ធ និងអាណត្តិរបស់សហគមន៍នេ - សាទ។** តាមរយៈការពង្រឹងការបន្តអាណត្តិដែលមានសុវត្ថិភាពរបស់សហគមន៍នេសាទ និងការគ្រប់គ្រងរួមគ្នាសហគមន៍មូលដ្ឋាន សហការជាមួយរាជរដ្ឋាភិបាល នឹងជួយគាំទ្រ ក៏ដូចជារក្សាសុខភាពនៃប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងជាបន្តបន្ទាប់ ហើយក្នុងពេលជាមួយគ្នា អាចទទួលបានភាគផលពីមុខរបរចិញ្ចឹមជីវិត ផ្អែកលើធនធានធម្មជាតិយ៉ាងជាប់លាប់។ គោលបំណងទាំងពីរនេះ មិនត្រឹមតែលើកកម្ពស់ភាពធន់របស់សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកយ៉ាងសំខាន់ ដល់កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុផងដែរ។ ពាក់ព័ន្ធនឹងចំណុចនេះ ការងាររបស់ Landesa តាមរយៈអង្គការដៃគូក្នុងស្រុក រួមមាន៖

## *អាណត្តិនៃការគ្រប់គ្រងថែរក្សាតំបន់និងអាស្រ័យផលធនធានប្រកបដោយសុវត្ថិភាព*

- **ការរៀបចំឡើងវិញនូវផែនទីស្តីពីការប្រើប្រាស់ដីនិងទឹករបស់សហគមន៍នេសាទ** ដើម្បីចាត់ថ្នាក់ **តំបន់នានាឱ្យបានច្បាស់លាស់**ក្នុងវង្វង់ព្រំប្រទល់សហគមន៍នេសាទ និង**ពង្រឹងផែនការគ្រប់គ្រងសហគមន៍នេសាទ** ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍ផ្នែកបរិស្ថាន និងការអភិវឌ្ឍ។ ទន្ទឹមពេលដែលមានកិច្ចខិតខំប្រឹងប្រែងរៀបចំផែនទីឡើងវិញនេះ ក៏មានការកំណត់ព្រំប្រទល់សហគមន៍នេសាទច្បាស់លាស់ ដោយមានការអនុម័តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ។
- **បំពេញបន្ថែមផែនការគ្រប់គ្រងសហគមន៍នេសាទ ជាមួយនឹងផែនការតាមដានធនធាន និងល្បាតរួមគ្នា សម្រាប់អាជ្ញាធរអនុវត្តច្បាប់។** អភិក្រមជាយុទ្ធសាស្ត្រ ដែលនៅពីក្រោយផែនការនេះ ត្រូវបានរៀបចំឡើង ផ្អែកលើភាពចាំបាច់ក្នុងការផ្តួបកម្លាំងកិច្ចខិតខំប្រឹងប្រែងរបស់សមាជិកសហគមន៍នេសាទ ខណ្ឌរដ្ឋបាលជលផល និងអង្គភាពនគរបាលមូលដ្ឋាន ក្នុងការល្បាត និងរាយការណ៍ព័ត៌មាន ដើម្បីទប់ស្កាត់សកម្មភាពខុសច្បាប់។

## *ការលើកកម្ពស់ និងគំនិតផ្តួចផ្តើមអភិបាលកិច្ច*

- **បង្កើតវេទិកាទំនាក់ទំនងដែលមានលក្ខណៈបរិយាបន្ន** ដែលសមាជិក និងតំណាងសហគមន៍នេសាទ ថ្នាក់ខេត្ត និងថ្នាក់ក្រោមជាតិ អាចចូលរួមដល់ការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ។
- **ពង្រឹងសមត្ថភាព និងជំនាញរបស់សមាជិកសហគមន៍នេសាទ**ស្តីពីការគ្រប់គ្រងព្រៃកោងកាងប្រកបដោយចីរភាព ការតាមដានធនធាន ការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចប្រកបដោយចីរភាព និងការទំនាក់ទំនង។
- **ពង្រឹងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព** ដែលនឹងជួយបំពេញតម្រូវការរបស់សហគមន៍នេសាទ ក្នុងគោលបំណងដោះស្រាយធនធានដែលមានកម្រិត មិនអាចរ៉ាប់រងលើចំណាយសម្រាប់ការងារអភិរក្សបាន។

សកម្មភាពទាំងអស់ខាងលើ មានគោលបំណងផ្តល់ឱកាសឱ្យស្ត្រី បុរស និងយុវជន ចូលរួមប្រកបដោយអត្ថន័យ ហើយស្របពេលជាមួយគ្នាពិចារណាយ៉ាងប្រុងប្រយ័ត្នលើផលប៉ះពាល់ ដែលបទដ្ឋានយេនឌ័រ មានលើសហគមន៍មូលដ្ឋាន។

# គោលបំណង

គោលបំណងចម្បងនៃរបាយការណ៍នេះ គឺដើម្បីពិពណ៌នាអំពីឥទ្ធិពលនៃការអភិរក្សព្រៃកោងកាង និងស្មៅសមុទ្រ និងគំនិតផ្តួចផ្តើមដាំព្រៃកោងកាង លើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ កិច្ចខិតខំប្រឹងប្រែងទាំងនេះកាន់តែរឹងមាំ នៅពេលដែលមានការពង្រឹងអាណាត្តិសហគមន៍ និងសុវត្ថិភាពដែនដី និងការលើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិរួមគ្នា ដែលសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងសហការរវាងសហគមន៍នេសាទនៅតំបន់ឆ្នេរ និងរាជរដ្ឋាភិ-បាល។ តាមរយៈការវាយតម្លៃលើសក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ របាយការណ៍នេះមានគោលបំណងបង្ហាញអំពី សារៈសំខាន់ និងភាពពាក់ព័ន្ធនៃសហគមន៍នេសាទតំបន់ឆ្នេរ ដើម្បីសម្រេច មហិច្ឆការបស់កម្ពុជា ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចបញ្ជាក់នៅក្នុងរបាយការណ៍ស្តីពីការរួមចំណែកថ្នាក់ជាតិក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (NDC) ដែលត្រូវបានធ្វើបច្ចុប្បន្នភាព។

# វិធីសាស្រ្ត

សម្រាប់ការប៉ាន់ប្រមាណពីសក្តានុពលនៃការកាត់បន្ថយការបញ្ចេញកាបូនពីសកម្មភាពអភិរក្សព្រៃកោងកាង និងស្មៅសមុទ្រ និងការដាំព្រៃកោងកាង **របាយការណ៍នេះបានប្រើប្រាស់ឧបករណ៍កំណត់ពីតុល្យភាពកាបូនជាមុន (Ex-Ante Carbon Balance Tool** - EX-ACT) v9.4 ដែលត្រូវបានបង្កើតឡើងដោយអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO)។ ការយកឧបករណ៍នេះមកប្រើប្រាស់ គឺដោយសារតែឧបករណ៍នេះត្រូវបានប្រើប្រាស់ ដើម្បីរៀបចំចំណាក NDC សម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត (FOLU) ក្នុងNDC ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់កម្ពុជា(២០២០)។

ទិន្នន័យបឋម ដែលចាំបាច់ ដើម្បីអាចអនុវត្តវិធីសាស្ត្រវាយ**តម្លៃកម្រិត ១ (Tier 1)** [2] ត្រូវបានប្រមូលតាមរយៈការជួបប្រាស្រ័យទាក់ទងជាច្រើនជាមួយសហគមន៍នេសាទ និងការិយាល័យរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់។ ដើម្បីសម្រេចបាននូវការវាយតម្លៃដែលសមស្របជាងមុន**កម្រិត២ (Tier 2)**[3] ត្រូវបានកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីស្តុកកាបូនសរុបនៃប្រព័ន្ធអេកូឡូស៊ីរបស់កម្ពុជាសម្រាប់ព្រៃកោងកាង យោងតាម Sharma S., et al (2020) (សូមមើលឧបសម្ព័ន្ធទី 1) ។ នៅខែមិថុនា ឆ្នាំ ២០២៤ Landesa បានធ្វើទស្សនកិច្ចទៅកាន់មូលដ្ឋាន និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ចំនួនពីរ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យជាមួយអាជ្ញាធរខេត្ត និងសមាជិកគណៈកម្មការសហគមន៍នេសាទ។ នៅខែតុលា ឆ្នាំ 2024 Landesa និងអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) បានរៀបចំសិក្ខាសាលាមួយដើម្បីផ្ទៀងផ្ទាត់របាយការណ៍លទ្ធផលដែលបានរកឃើញជាមួយតំណាងរដ្ឋាភិបាលសំខាន់ៗ។

2 តម្លៃលំនាំដើមរបស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (International Panel for Climate Change - IPCC) និងទិន្នន័យបានពីឯកសារពាក់ព័ន្ធដែលត្រូវបានដាក់ឆ្លងការពិនិត្យឡើងវិញដោយអ្នកជំនាញផ្សេងទៀត។

3 តម្លៃភាគហ៊ុនកាបូនដាក់លាក់ក្នុងតំបន់ និងមេគុណបំភាយឧស្ម័ន។

# កាបូនខៀវ និងការរួមចំណែកថ្នាក់ជាតិដែលបានកំណត់របស់កម្ពុជា

## កាបូនខៀវនៅកម្ពុជា

ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ និងសមុទ្រ ដូចជាព្រៃកោងកាង វាលភក់ទឹកប្រៃ និងវាលស្មៅសមុទ្រ មានប្រសិទ្ធភាពក្នុងការស្រូបយក និងស្តុកឧស្ម័នកាបូនិចពីបរិយាកាស ($CO_2$)។ **កាបូនខៀវសំដៅលើកាបូន**ដែលស្តុកនៅក្នុងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ និងសមុទ្រ ដែលអាចស្តុកកាបូនបានរហូតដល់ ៥ ដងច្រើនជាងព្រៃនៅតំបន់ខ្ពង់រាប (សូមមើលរូបភាពទី ២) (TNC, 2024)។

*រូបភាពទី 2. ការប្រៀបធៀបការស្រូបយកកាបូនប្រចាំឆ្នាំ*




***កំណត់សម្គាល់៖*** *tCO2e ក្នុងមួយហិកតា និងក្នុងមួយឆ្នាំ រវាងប្រព័ន្ធអេកូឡូស៊ីកាបូនខៀវ (ស្មៅសមុទ្រ ព្រៃកោងកាង និងវាលភក់ទឹកប្រៃ) និងព្រៃត្រូពិច។*

***ប្រភព៖*** *(Mcleod & et al., 2011).*

យោងតាមអង្គការឃ្លាំមើលព្រៃកោងកាងសកល (GMW) **កាបូនសរីរាង្គសរុប ដែលស្តុកក្នុងព្រៃកោងកាងនៅកម្ពុជា** ត្រូវបានប៉ាន់ប្រមាណថាមានចំនួន 76.21 $MtCO_2e$[4] ក្នុងនោះ 10.53 $MtCO_2e$ ត្រូវបានស្តុកនៅក្នុងជីវម៉ាសលើដី និង 65.68 $MtCO_2e$ ត្រូវបានស្តុកនៅក្នុងដីជម្រៅ ១ ម៉ែត្រខាងលើ (សូមមើលរូបភាពទី ៣)។ នៅក្នុងឆ្នាំ២០២០ Sharma S., et al., បានប៉ាន់ប្រមាណថា មធ្យមភាគស្តុកកាបូននៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងព្រៃកោងកាងក្នុងប្រទេសកម្ពុជាគឺ 784.7 ± 30.1 Mg C/ha$^2$ ដែលស្ថិតនៅក្នុងចន្លោះ (355-1,385 Mg C/ha) ដែលបានរាយការណ៍នៅក្នុងអក្សរសិល្ប៍ព្រៃកោងកាង។

នៅពេលនិយាយអំពីការកាត់បន្ថយ **មានការប៉ាន់ប្រមាណថា ការកាត់បន្ថយការបញ្ចេញឧស្ម័នធំបំផុតក្នុងមួយហិកតា នៃតំបន់ព្រៃឈើក្នុងប្រទេស ត្រូវបានប៉ាន់ប្រមាណថា អាចមានប្រភពចេញពីការកាត់បន្ថយការបាត់បង់ព្រៃកោងកាង** (1,344.33 $tCO_2e$/ហិកតា) និងការស្តារព្រៃកោងកាងឡើងវិញ (632.22 $tCO_2e$/ហិកតា) ជាពិសេស នៅពេលប្រៀបធៀបជាមួយនឹងការអន្តរាគមន៍ផ្សេងទៀត នៅក្នុងតំបន់ព្រៃឈើផ្សេងទៀត[5] (សូមមើលរូបភាពទី ៤)(GMW, ២០២៤)។

រូបភាពទី 3. កាបូនខៀវព្រៃកោងកាងនៅកម្ពុជា (២០១៦) (បរិមាណ និងដង់ស៊ីតេនៃកាបូនដែលស្តុកនៅក្នុងជីវម៉ាស និងដីព្រៃកោងកាង)។

[4] លានគិតសមមូលជាតោនឧស្ម័នកាបូនិច។

[5] ព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីផ្សេងទៀត (ឧទាហរណ៍ វាលស្មៅ ដីភក់)។ វាមិនរាប់បញ្ចូលតម្លៃទាក់ទងនឹងកសិកម្ម ជីវថាមពល ឬវិធានការនៅខាងផ្នែកតម្រូវការ (ឧទាហរណ៍ កាកសំណល់អាហារ)។




*ប្រភព៖ (GMW, 2024).*




*ប្រភព៖ (GMW, 2024).*

រូបភាពទី 4. ការកាត់បន្ថយការបញ្ចេញឧស្ម័នពីព្រៃកោងកាងនៅកម្ពុជា (២០១៦) (ការប៉ាន់ប្រមាណពីសក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន)។

## ចំណាកសម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀតក្នុង NDC របស់កម្ពុជា

**NDC ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់កម្ពុជា (២០២០) បានដាក់ចេញគោលដៅប្រកបដោយមហិច្ឆតា សម្រាប់វិស័យព្រៃឈើ[6] និងការប្រើប្រាស់ដីផ្សេងទៀត (FOLU)** ដើម្បីកាត់បន្ថយអត្រានៃការកាប់បំផ្លាញព្រៃឈើឱ្យបានពាក់កណ្តាលត្រឹមឆ្នាំ ២០៣០ ស្របតាមយុទ្ធសាស្ត្ររេដបូក (REDD+)[7] របស់កម្ពុជា។ NDC បច្ចុប្បន្នភាពក៏យកចិត្តទុកដាក់ជាពិសេសលើយេនឌ័រ និងក្រុមងាយរងគ្រោះ ដោយធានាថាសកម្មភាព បន្ស៊ាំ និងកាត់បន្ថយការបញ្ចេញឧស្ម័ន រួមចំណែក កសាងសង្គមមួយដែលកាន់តែមានបរិយាបន្ន (KoC, 2020)។

បើតាមចំណាកនៃការបញ្ចេញឧស្ម័នតាមទម្លាប់ធម្មតា (BAU) សម្រាប់ប្រទេសកម្ពុជា ការបញ្ចេញឧស្ម័នសរុបនៅឆ្នាំ ២០៣០ ដោយមិនរាប់បញ្ចូលវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត រំពឹងថានឹងកើនឡើងរហូតដល់ 79 MtCO2e/ឆ្នាំ ខណៈដែលការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប ដែលមានបញ្ចូលវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត រំពឹងថានឹងកើនឡើងដល់ 155 MtCO2e/ឆ្នាំ ។ **វិស័យព្រៃឈើនិងការប្រើប្រាស់ដីផ្សេងទៀត នឹងបង្កើតការបញ្ចេញឧស្ម័នតាមទម្លាប់ធម្មតាសរុបខ្ពស់បំផុត** (៤៩,២%) នៅឆ្នាំ ២០៣០ បន្ទាប់មកគឺវិស័យថាមពល (២២,២%) វិស័យកសិកម្ម (១៧,៥%) ឧស្សាហកម្ម (៩,០%) និងវិស័យសំណល់ (២,១%) (សូមមើលរូបភាពទី ៥)(KoC, 2020)។

ជាការឆ្លើយតបចំពោះចំណុចនេះ **NDC បច្ចុប្បន្នភាពរបស់កម្ពុជា បានកំណត់ចំណុចដៅកាត់បន្ថយការបញ្ចេញឧស្ម័នកន្លងមក ពីវិស័យព្រៃឈើឱ្យបាន ៥០% ត្រឹមឆ្នាំ ២០៣០**។ នេះស្មើនឹងការ

---

6 ព្រៃកោងកាងរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាព្រៃឈើ។

7 ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ ការអភិរក្សស្តុកកាបូនព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការបង្កើនស្តុកកាបូនព្រៃឈើ។

កាត់បន្ថយជាមធ្យមប្រចាំឆ្នាំចំនួន 21.54 MtCO2e/ឆ្នាំ។ ក្រោមចំណាកនេះ[8] វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត រំពឹងថានឹងរួមចំណែកធំបំផុត បើប្រៀបធៀបជាមួយវិស័យផ្សេងទៀត ពោលគឺកាត់បន្ថយការបញ្ចេញឧស្ម័ន ៥៩,១% ត្រឹមឆ្នាំ ២០៣០។

រូបភាពទី 5. ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមទម្លាប់ធម្មតា នៅឆ្នាំ ២០៣០ - បញ្ចូលវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត។




*ប្រភព៖* (*KoC, 2020*).

ដើម្បីសម្រេចចំណុចដៅនេះ រដ្ឋាភិបាលបានប្តេជ្ញាកែលម្អការគ្រប់គ្រង និងតាមដានធនធានព្រៃឈើ និងការប្រើប្រាស់ដីព្រៃឈើ ពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ កសាងសមត្ថភាព និងចូលរួមសហការជាមួយភាគីពាក់ព័ន្ធនានា[9] (KoC, 2020)។

8 មានតែចំណាក NDC មួយប៉ុណ្ណោះ សម្រាប់គ្រប់វិស័យទាំងអស់ លើកលែងតែវិស័យ FOLU។ វិស័យ FOLU មានចំណាក NDC ចំនួនបី - ចំណាកទី១៖ គម្របព្រៃឈើ ៦០% ត្រឹមឆ្នាំ២០៣០; ចំណាកទី២៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នកន្លងមកឱ្យបាន ៥០% ត្រឹមឆ្នាំ២០៣០; និងចំណាកទី៣៖ ការកាត់បន្ថយការបញ្ចេញឧស្ម័ន INDC។ ចំណាកទី២ ត្រូវបានបង្ហាញនៅក្នុង NDC ជាផ្នែកមួយនៃគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដ្បិតអភិក្រមនេះនឹងមានភាពធន់ល្អជាងមុន នៅពេលដែលសកម្មភាពកាត់បន្ថយទទួលបរាជ័យ។

9 ផ្អែកលើរបាយការណ៍ពីតាមក្រសួងនា និងលេខាធិការដ្ឋានបច្ចេកទេស REDD+។ ក្រសួងដឹកនាំ គឺជាលេខាធិការដ្ឋានបច្ចេកទេស REDD+។




# ការបូនខៀវនៅសហគមន៍នេសាទកោះគ្រឹះស្នាលក

សហគមន៍នេសាទកោះគ្រឹះស្នាលក ស្ថិតនៅក្នុងខេត្តកំពត នៅតំបន់ឆ្នេរភាគខាងត្បូងនៃប្រទេសកម្ពុជា តាមបណ្តោយឈូងសមុទ្រថៃ។ សហគមន៍នេសាទគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ៥៩៣ ហិកតា រួមទាំងព្រៃ**កោងកាងប្រមាណ ៨៩ ហិកតា និងស្មៅសមុទ្រប្រមាណ ៩២ ហិកតា នៅតំបន់ទឹករាក់**និងទឹកជ្រៅ (សូមមើលរូបភាពទី ៦)។ តំបន់នេះស្ថិត**នៅកម្ពស់ ២,២៦ ម៉ែត្រជាមធ្យម លើកម្ពស់ទឹកសមុទ្រ ដោយមានព្រៃកោងកាង** នៅតាមបណ្តោយឆ្នេរសមុទ្រ (FAO, 2024)។ ។ ដីនៅតំបន់នេះជា**ប្រភេទដី gleysol (ដីសើម)** (FAO, 2024) ជាមួយនឹងអាកាសធាតុត្រូពិច ដែលមាន**សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ ២៧,៦ អង្សាសេ និងកម្រិតទឹកភ្លៀងមធ្យមប្រចាំឆ្នាំ ១.៨៤០,៣៤ មីលីម៉ែត្រ** (FAO, 2024)។

រូបភាពទី 6. ផែនទីសហគមន៍នេសាទកោះគ្រឹះស្នាលក




*ប្រភព៖ រដ្ឋបាលជលផល។*

បើតាមអង្គការឃ្លាំមើលព្រៃកោងកាងសកល (GMW)[10] នៅឆ្នាំ ២០២០ **ដង់ស៊ីតេ ជីវម៉ាសលើដីជាមធ្យមនៃព្រៃកោងកាង** ក្នុងសហគមន៍នេសាទមានប្រមាណ **៧៤ តោនក្នុងមួយហិកតា** ស្មើនឹងប្រមាណ ៧០% នៃដង់ស៊ីតេជីវម៉ាសលើដីនៃព្រៃកោងកាងជាមធ្យមរបស់កម្ពុជា ដែលមានចំនួន ១០៥,៥៩ តោន ក្នុងមួយហិកតា។ **កម្ពស់កាណូភី (canopy) អតិបរមាជាមធ្យមនៃព្រៃកោងកាង**នៅក្នុងសហគមន៍នេសាទនៅឆ្នាំ ២០២០ មានប្រមាណ **៤,៦ ម៉ែត្រ** ស្មើនឹងប្រមាណ ៥៥% នៃកម្ពស់កាណូភីអតិបរមានៃព្រៃកោងកាងជាមធ្យម របស់កម្ពុជានៅក្នុងឆ្នាំដូចគ្នា ដែលមានចំនួន ៨,៤៨ ម៉ែត្រ។

## ការវាយតម្លៃតុល្យភាពកាបូនខៀវ

បន្ទាប់ពីបានពិចារណាលើទិន្នន័យ EX-ACT រួចមក កត្តាខាងក្រោមនេះត្រូវបានប្រើប្រាស់ សម្រាប់វាយតម្លៃលើតុល្យភាពកាបូនខៀវ៖

១. **អាកាសធាតុ៖** ត្រូពិច
២. **សំណើម៖** សើម
៣. **ប្រភេទដី៖** ដីសើម
៤. **រយៈពេលសរុបនៃការគណនា៖** ២០ ឆ្នាំ[11]
៥. **ដំណាក់កាលអនុវត្ត៖** ៤ ឆ្នាំ (២០២៣-២០២៦ - រយៈពេលអនុវត្តគម្រោង)
៦. **ដំណាក់កាលកសាងទុន (Capitalization)៖** ១៦ ឆ្នាំ (រយៈពេល ១៦ ឆ្នាំ ត្រូវបានកំណត់សម្រាប់រយៈពេលសរុបនៃការគណនា ២០ ឆ្នាំ ដែលជារយៈពេល ដើម្បីទទួលបាននូវលំនឹង (equilibrium) ថ្មី បន្ទាប់ពីការអន្តរាគមន៍លើដីណាមួយ)
៧. **ប្រភេទព្រៃ៖** ព្រៃកោងកាង
៨. **ទំហំ និងស្ថានភាពព្រៃ៖** ព្រៃកោងកាងប្រមាណ ៨៩ ហិកតា[12] មានភាពរេចរិលពីកម្រិតទាបទៅមធ្យម។[13]

---

[10] ទិន្នន័យផ្អែកលើវិសាលភាពព្រៃកោងកាងជាសកល ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ២០១៦ (Bunting et al. 2018) រួមផ្សំជាមួយកម្ពស់កាណូភី និងទំនាក់ទំនងអាឡូមេទ្រិក (allometric relationships) របស់ Simard et al។

[11] រយៈពេលសរុបនៃគម្រោងមួយជាទូទៅត្រូវបានសន្មត់ថាស្មើនឹង ២០ ឆ្នាំ ដោយអនុលោមតាមអនុសាសន៍របស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC, 2006)។ រយៈពេល ២០ ឆ្នាំនេះគឺជាផលបូកនៃដំណាក់កាលពីរ គឺ**ដំណាក់កាលអនុវត្តគម្រោង** (ពេលគឺដំណាក់កាលសកម្មនៃគម្រោង) និង**ដំណាក់កាលកសាងទុន** (ពេលគឺរយៈពេលសម្រាប់សម្រេចបាននូវតុល្យភាពថ្មីបន្ទាប់ពីការធ្វើអន្តរាគមន៍)។

[12] កម្រិតរេចរិលនៃព្រៃឈើ៖ គ្មានទៅតិចតួច (បាត់បង់ជីវម៉ាស់ 0% ទៅ ១០%); **ទាប** (បាត់បង់ជីវម៉ាស់ប្រមាណ ២០%); **មធ្យម** (បាត់បង់ជីវម៉ាស់ប្រមាណ ៤០%); និងធ្ងន់ធ្ងរទៅធ្ងន់ធ្ងរបំផុត (បាត់បង់ជីវម៉ាស់លើសពី ៦០%)។

[13] កម្រិតរេចរិលផ្អែកលើស្ថានភាពប្រៀបធៀបនៃដង់ស៊ីតេជីវម៉ាស់ និងកម្ពស់កាណូភី ធៀបនឹងមធ្យមភាគរបស់ប្រទេសកម្ពុជា។

៩. **ការគំរាមកំហែងបណ្តាលមកពីការប្រើប្រាស់ដី៖** នៅក្នុងសហគមន៍នេសាទ **តំបន់ព្រៃកោងកាងខាងក្រោម** កំពុងរងការគំរាមកំហែងដោយ៖

   ក. ការផ្លាស់ប្តូរការប្រើប្រាស់ដី - ព្រៃកោងកាងប្រមាណ ២១ ហិកតា - លទ្ធភាពដែលអាចមានភ្លើងឆេះព្រៃគឺ**គ្មាន**

   ខ. ការរេចរិលដី - ព្រៃកោងកាងប្រមាណ ៦៨ ហិកតា ដោយសារការបំពុល និងសកម្មភាពខុសច្បាប់ ជាពិសេសនៅតាមព្រំប្រទល់នៃសហគមន៍នេសាទ។

១០. **ការសន្មត់៖** ដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចកើតមាន បណ្តាលមកពីគម្រោង មានការពិចារណាលើការសន្មតដូចខាងក្រោម ផ្អែកលើសកម្មភាព និងវិធីសាស្ត្រ ដែលត្រូវបានស្នើឡើងដោយ Landesa និងដៃគូក្នុងស្រុករបស់ខ្លួន សម្រាប់ការងាររួមគ្នានៅក្នុងសហគមន៍នេសាទ៖

   ក. តាមរយៈការធ្វើផែនទី ការកំណត់ព្រំប្រទល់ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ និងការគាំទ្រការអភិវឌ្ឍសមត្ថភាព គម្រោងនេះនាំឱ្យមានការការពារដោយជោគជ័យ និងបញ្ចៀសការបំផ្លាញ និងរេចរឹលដីព្រៃកោងកាង ក្នុងសហគមន៍នេសាទ។

   ខ. ការពង្រឹងអាណត្តិរបស់សហគមន៍នេសាទ និងការអនុវត្តផែនការគ្រប់គ្រងតំបន់ស្មៅសមុទ្រប្រកបដោយចីរភាពរបស់រដ្ឋបាលជលផល (២០២៤-២០២៨) នាំឱ្យមានការបញ្ចៀសការបំផ្លាញស្មៅសមុទ្រ។

   គ. តាមរយៈការពង្រឹងអាណត្តិរបស់សហគមន៍នេសាទ គម្រោងនេះលើកទឹកចិត្តឱ្យមានការដាំព្រៃកោងកាងលើផ្ទៃដី ២២ ហិកតា ដែលត្រូវបានកំណត់ សម្រាប់ការស្តារឡើងវិញនៅក្នុងសហគមន៍នេសាទ។[14]

## លទ្ធផលនៃតុល្យភាពកាបូនខៀវ

ប្រសិនបើអាណត្តិរបស់សហគមន៍នេសាទត្រូវបានពង្រឹង ហើយសមាជិករបស់ខ្លួន រួមជាមួយរដ្ឋាភិបាល ទទួលបានជោគជ័យក្នុងកិច្ចសហការបញ្ចៀសការបំផ្លាញ និងការរេចរិលដីព្រៃកោងកាង និងស្មៅសមុទ្រ ព្រមទាំងការដាំព្រៃកោងកាងឡើងវិញ **សក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សុទ្ធសរុបដែលត្រូវបានប៉ាន់ប្រមាណគឺ 66,785** $tCO_2e$[15] (ប្រសិនបើរយៈពេលសរុបសម្រាប់ការគណនា ២០ ឆ្នាំ)។ នេះស្មើនឹង**លទ្ធភាពកាត់បន្ថយជាមធ្យមប្រចាំឆ្នាំចំនួន 3,339** $tCO_2e$ **ឬ 18.7** $tCO_2e$ **ក្នុងមួយហិកតា។ សក្តានុពលនៃការកាត់បន្ថយ**សរុប (តុល្យភាព) កើតចេញពីការ**បញ្ចៀសការបញ្ចេញឧស្ម័នពីការបំផ្លាញ** និងរេចរឹលដី និងស្មៅសមុទ្រ (65,148 $tCO_2e$) ព្រមទាំង**ការបញ្ចេញ - ឧស្ម័នដែលបានស្រូបយក** ពីការដាំព្រៃកោងកាងឡើងវិញ (1,636 $tCO_2e$ ) (សូមមើលរូបភាពទី ៧) ។

[14] អត្រារស់ ដែលត្រូវបានរាយការណ៍ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញបច្ចុប្បន្ន មានប្រមាណជា ៤០%។

[15] គិតសមមូលជាតោនឧស្ម័នកាបូនិច។

រូបភាពទី 7. លំហូរសុទ្ធ គិតជា $tCO_2e$




ផ្អែកលើចំណុចដៅដែលបានកំណត់ក្នុង NDC របស់កម្ពុជាសម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត ត្រឹមឆ្នាំ ២០៣០ សក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពីការពង្រឹងអាណត្តិ និងការគ្រប់គ្រងរួមគ្នាលើធនធានរបស់សហគមន៍នេសាទកោះគ្រឹះស្នាលក អាចរួម**ចំណែក ០,០១៦%** នៃការកាត់បន្ថយជាមធ្យមប្រចាំឆ្នាំ ដែលត្រូវបានកំណត់ជាគោលដៅ (**21.54 $MtCO_2e$/ឆ្នាំ**) ពីវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត។




# កាបូនខៀវនៅតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់

តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ តាមតំបន់ឆ្នេរនៃប្រទេសកម្ពុជា។ តំបន់គ្រប់គ្រងជលផលសមុទ្រគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ១០.៩២៣ ហិកតា រួមទាំង**ព្រៃកោងកាងប្រមាណ ២.៨៧៦ ហិកតា និងស្មៅសមុទ្រ ២** ហិកតានៅតាមបណ្តោយឈូងសមុទ្រវាលវិញ (សូមមើលរូបភាពទី ៨)។ តំបន់នេះស្ថិត**នៅកម្ពស់ ១,៥៥ ម៉ែត្រ ជាមធ្យមលើកម្ពស់ទឹកសមុទ្រ** (FAO, 2024)។ ដីតំបន់នេះក៏ជា**ប្រភេទដី** gleysol **(ដីសើម)** (FAO, 2024) និងអាកាសធាតុត្រូពិចដែលមាន**សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ ២៥,៥ អង្សាសេ** និង**កម្រិតទឹកភ្លៀងមធ្យមប្រចាំឆ្នាំ ២.៦១១,៣ មីលីម៉ែត្រ** (FAO, 2024).

បើតាម GMW នៅឆ្នាំ ២០២០ **ដង់ស៊ីតេជីវម៉ាសលើដីជាមធ្យមនៃព្រៃកោងកាង** នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រមានប្រមាណ **៩៩ តោនក្នុងមួយហិកតា** ស្មើនឹងប្រមាណ ៩៤% នៃដង់ស៊ីតេ

ដីវម៉ាសលើដីនៃព្រៃកោងកាងជាមធ្យម របស់កម្ពុជា ដែលមានចំនួន ១០៥,៥៩ តោនក្នុងមួយហិកតា។ **កម្ពស់កាណូភីអតិបរមាជាមធ្យមនៃព្រៃកោងកាង**នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅឆ្នាំ ២០២០ មានប្រមាណ **៧,៨ ម៉ែត្រ** ស្មើនឹងប្រមាណ ៩២% នៃកម្ពស់កាណូភីអតិបរមានៃព្រៃកោងកាងជាមធ្យម របស់កម្ពុជានៅក្នុងឆ្នាំដូចគ្នា ដែលមានចំនួន ៨,៤៨ ម៉ែត្រ។

រូបភាពទី ៨. ផែនទីតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

## ការវាយតម្លៃតុល្យភាពកាបូនខៀវ

បន្ទាប់ពីបានពិចារណាលើទិន្នន័យ EX-ACT រួចមក កត្តាខាងក្រោមនេះត្រូវបានប្រើប្រាស់ សម្រាប់វាយតម្លៃលើតុល្យភាពកាបូនខៀវ៖

១. **អាកាសធាតុ៖** ត្រូពិច

២. **សំណើម៖** សើម

៣. **ប្រភេទដី៖** ដីសើម

**រយៈពេលសរុបនៃការគណនា៖** ២០ ឆ្នាំ[16]

៤. **ដំណាក់កាលអនុវត្ត៖** ៤ ឆ្នាំ (២០២៣-២០២៦ - រយៈពេលអនុវត្តគម្រោង)

៥. **ដំណាក់កាលកសាងទុន (Capitalization)៖** ១៦ ឆ្នាំ (រយៈពេល ១៦ ឆ្នាំ ត្រូវបានកំណត់សម្រាប់រយៈពេលសរុបនៃការគណនា ២០ ឆ្នាំ ដែលជារយៈពេល ដើម្បីទទួលបាននូវលំនឹង (equilibrium) ថ្មី បន្ទាប់ពីការអន្តរាគមន៍លើដីណាមួយ)

៦. **ប្រភេទព្រៃ៖** ព្រៃកោងកាង

[16] ជាទូទៅ រយៈពេលសរុបនៃគម្រោងមួយត្រូវបានសន្មត់ថាស្មើនឹង ២០ ឆ្នាំ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC, 2006)។ រយៈពេល ២០ ឆ្នាំនេះ គឺជាផលបូកនៃដំណាក់កាលពីរ គឺ**ដំណាក់កាលអនុវត្តគម្រោង** (ពេលគឺដំណាក់កាលសកម្មនៃគម្រោង) និង**ដំណាក់កាលកសាងទុន** (ពេលគឺរយៈពេលដើម្បីសម្រេចបាននូវតុល្យភាពថ្មីបន្ទាប់ពីការធ្វើអន្តរាគមន៍)។

៧. **ទំហំ និងស្ថានភាពព្រៃ៖** ព្រៃកោងកាងប្រមាណ ២.៨៧៦ ហិកតា[17] ដែលរេចរិលក្នុងកម្រិតទាបបំផុត។[18]

៨. **ការគំរាមកំហែងនៃការប្រើប្រាស់ដី៖** ព្រៃកោងកាង ក្នុងភាគរយប៉ាន់ស្មានខាងក្រោម ត្រូវបានកំណត់ថាស្ថិតក្រោមការគំរាមកំហែង ប្រសិនបើគ្មានការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រ៖

ក. ការរេចរិលដី - បច្ចុប្បន្ន ព្រៃកោងកាងប្រមាណ **៣៨%** ត្រូវបានកំណត់ជាតំបន់ស្នូល និងទ្រនាប់នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់។

ខ. ការផ្លាស់ប្តូរការប្រើប្រាស់ដី និងការរេចរិល បច្ចុប្បន្ន ព្រៃកោងកាងប្រមាណ **២៩%** ត្រូវបានគំរាមកំហែង ដោយសកម្មភាពវារីវប្បកម្ម (ភាគច្រើនការចិញ្ចឹមក្ដាម)។

៩. **ការសន្មត់៖** ដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចកើតចេញពីគម្រោង មានការពិចារណាលើការសន្មត់ដូចខាងក្រោម ផ្អែកលើសកម្មភាព និងអភិក្រម ដែលត្រូវបានស្នើឡើងដោយ Landesa និងដៃគូក្នុងស្រុករបស់ខ្លួន សម្រាប់អនុវត្តការងាររួមគ្នានៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ៖

ក. តាមរយៈការធ្វើផែនទី ការកំណត់ព្រំប្រទល់ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ និងការគាំទ្រការអភិវឌ្ឍសមត្ថភាព គម្រោងនេះនាំឱ្យមានការការពារដោយជោគជ័យ និងបញ្ចៀសការបំផ្លាញ និងរេចរិលដីព្រៃកោងកាងនៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ។

ខ. ការពង្រឹងអាណត្តិរបស់សហគមន៍នេសាទ និងការគ្រប់គ្រងរួមគ្នាលើធនធាននៃតំបន់គ្រប់គ្រង ជលផលសមុទ្រនាំឱ្យមានការបញ្ចៀសការបំផ្លាញស្មៅសមុទ្រ។

គ. គម្រោងនេះ តាមរយៈអាណត្តិរបស់សហគមន៍នេសាទ នាំឱ្យមានការលើកទឹកចិត្តដល់ការដាំព្រៃកោងកាងលើផ្ទៃដីប្រមាណ ៧,៥ ហិកតាក្នុងមួយឆ្នាំ ដែលសមស្របសម្រាប់ការស្តារព្រៃកោងកាងឡើងវិញ[19] ក្នុងអំឡុងពេលអនុវត្តគម្រោង។[20]

## លទ្ធផលនៃតុល្យភាពកាបូនខៀវ

ប្រសិនបើអាណត្តិការពារដីធ្លីរបស់សហគមន៍នេសាទ នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រត្រូវបានពង្រឹង ហើយសមាជិករបស់ខ្លួន រួមជាមួយរដ្ឋាភិបាល ទទួលបានជោគជ័យក្នុងកិច្ចសហការបញ្ចៀសការបំផ្លាញ និងរេចរិលដីព្រៃកោងកាង និងស្មៅ-

---

[17] កម្រិតរេចរឹលនៃព្រៃឈើ៖ **គ្មានទៅតិចតួច** (បាត់បង់ដីវ៉ាស់ ០% ទៅ ១០%); ទាប (បាត់បង់ដីវ៉ាស់ប្រមាណ ២០%); មធ្យម (បាត់បង់ដីវ៉ាស់ប្រមាណ ៤០%); និងធ្ងន់ធ្ងរទៅធ្ងន់ធ្ងរបំផុត (បាត់បង់ដីវ៉ាស់លើសពី ៦០%)។

[18] កម្រិតរេចរិល ផ្អែកលើស្ថានភាពប្រៀបធៀបនៃដង់ស៊ីតេដីវ៉ាស់ និងកម្ពស់កាណូភី ធៀបនឹងមធ្យមភាគរបស់ប្រទេសកម្ពុជា។

[19] អត្រារស់ ដែលត្រូវបានរាយការណ៍ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញដូចបច្ចុប្បន្ន គឺប្រមាណជា ៨០%។

[20] កិច្ចខិតខំប្រឹងប្រែងស្តារព្រៃកោងកាងឡើងវិញ ឆ្លុះបញ្ចាំងតែលើផែនការដាំព្រៃកោងកាងរបស់សហគមន៍នេសាទប៉ុណ្ណោះ។ វាមិនរាប់បញ្ចូលកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញតាមគម្រោងផ្សេងទៀត ដែលធ្វើឡើងដោយរដ្ឋាភិបាល និង/ឬអង្គការផ្សេងទៀតឡើយ។

សមុទ្រ ព្រមទាំងការដាំព្រៃកោងកាងឡើងវិញ សក្តានុពលនៃការកាត់បន្ថយ**ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សុទ្ធសរុប ត្រូវបានប៉ាន់ប្រមាណមានចំនួន 863,344 $tCO_2e$**[21] ជាមួយនឹងរយៈពេលសរុបសម្រាប់គណនា ២០ ឆ្នាំ។ មានន័យថា សក្តានុពលនៃការកាត់បន្ថយជាមធ្យមប្រចាំឆ្នាំ មានចំនួន **43,167 $tCO_2e$ ឬ 10.8 $tCO_2e$ ក្នុងមួយហិកតា។ សក្តានុពលនៃការកាត់បន្ថយសរុប** (តុល្យភាព) កើតចេញពីការបញ្ចៀស**ការបញ្ចេញឧស្ម័ន** ពីការបំផ្លាញ និងរេចរិលដី (859,160 $tCO_2e$ ) ព្រមទាំង**ការបញ្ចេញឧស្ម័ន**ដែលបានស្រូបយកពីការដាំព្រៃកោងកាងឡើងវិញ នៅតំបន់ដែលសមស្រប (4,183 tCO2e ) (សូមមើលរូបភាពទី ៩)។




រូបភាពទី 9. លំហូរសុទ្ធ គិតជា $tCO_2e$។

ផ្អែកលើចំណុចដៅដែលបានកំណត់ក្នុង NDC របស់កម្ពុជាសម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត ត្រឹមឆ្នាំ ២០៣០ សក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពីការពង្រឹងអាណត្តិ និងការគ្រប់គ្រងរួមគ្នាលើធនធានរបស់សហគមន៍នេសាទកោះគ្រឹះស្នាលក **អាចរួមចំណែក ០,២០%** នៃការកាត់បន្ថយជាមធ្យមប្រចាំឆ្នាំ ដែលត្រូវបានកំណត់ជាគោលដៅ (**21.54 $MtCO_2e$/ឆ្នាំ**) ពីវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត។

[21] គិតសមមូលជាតោនឧស្ម័នកាបូនិច។

# សេចក្តីសន្និដ្ឋាន

នៅតាមបណ្តោយឆ្នេរសមុទ្រនៃតំបន់អាស៊ីអាគ្នេយ៍ ដែលសហគមន៍នេសាទនៅតំបន់ឆ្នេរត្រូវបានផ្តល់ឱ្យនូវសិទ្ធិអំណាច ព្រមទាំងសិទ្ធិស្របច្បាប់ និងអំណាចក្នុងការគ្រប់គ្រងព្រៃកោងកាង អភិក្រមនេះត្រូវបានរកឃើញថាមានប្រសិទ្ធភាពក្នុងការកែលម្អការប្រើប្រាស់ទំនិញ និងសេវាព្រៃកោងកាង (Friess, Thompson, & et al., 2016) (Arifanti, Sidik, & et al., 2022)។ លើសពីនេះទៀត ការសហការគ្រប់គ្រងព្រៃកោងកាង បានបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចព្រៃកោងកាង ដោយបានកាត់បន្ថយថ្លៃចំណាយលើការគ្រប់គ្រងទំនិញសាធារណៈ និងបង្កើនអត្ថប្រយោជន៍រួមសម្រាប់អ្នកប្រើប្រាស់ធនធានក្នុងមូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយ ភស្តុតាងបង្ហាញថា ការផ្តល់ការគ្រប់គ្រងធនធានដល់សហគមន៍នេសាទនៅតំបន់ឆ្នេរ មិនមែនសុទ្ធតែអាចធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនោះទេ ជាពិសេសនៅពេលមានការគំរាមកំហែងពីខាងក្រៅដែលបង្កឡើងដោយភាគីពាក់ព័ន្ធដែលមានអំណាចខ្លាំង ឬដែលតម្រូវឱ្យមានការអនុវត្តច្បាប់ (Friess, Thompson, & et al., 2016)។

នៅក្នុងសហគមន៍នេសាទកោះគ្រឹះស្នាលក និងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ សមាជិកសហគមន៍បានងាកពីការកាប់ព្រៃកោងកាង ទៅជាការដាំ និងការពារព្រៃកោងកាង ស្របតាមផែនការគ្រប់គ្រងសហគមន៍នេសាទ។ ជាអកុសល អ្នកដែលមិនមែនជាសមាជិកសហគមន៍នេសាទ និងគម្រោងអភិវឌ្ឍន៍ថ្មីៗ កំពុងគំរាមកំហែងដល់ព្រៃកោងកាង និងស្មៅសមុទ្រ។ ការគំរាមកំហែងពីខាងក្រៅនេះ បានកេងចំណេញពីការកំណត់ព្រំប្រទល់ និងតំបន់មិនច្បាស់លាស់ កង្វះការសម្របសម្រួល ការគ្រប់គ្រង និងការការពារមានកម្រិតដើម្បីទាញយកធនធាន និងផ្លាស់ប្តូរការប្រើប្រាស់ដី។ ខណៈពេលដែលសហគមន៍នេសាទមានសិទ្ធិ និងសមត្ថភាពគ្រប់គ្រងធនធានស្របតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងសហគមន៍នេសាទ ការពង្រឹងអាណត្តិរបស់សហគមន៍នេសាទ និងការគ្រប់គ្រងរួមគ្នាលើធនធាន នៅតែជាកិច្ចការដ៏ចាំបាច់បំផុត។ គោលដៅនេះអាចសម្រេចទៅបាន តាមរយៈកិច្ចសហការរវាងសហគមន៍នេសាទ និងរដ្ឋាភិបាល។ កិច្ចសហការបែបនេះមានសារៈសំខាន់សម្រាប់សហគមន៍នេសាទ មិនត្រឹមតែ ដើម្បីធានានិរន្តរភាពនៃការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ពួកគេប៉ុណ្ណោះទេ ថែមទាំង ដើម្បីអភិរក្សព្រៃកោងកាង និងជម្រកស្មៅសមុទ្រប្រកបដោយប្រសិទ្ធភាពផងដែរ។

ក្រៅពីការបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចព្រៃកោងកាង និងស្មៅសមុទ្រ ការពង្រឹងសិទ្ធិថែរក្សាអាស្រ័យផល និងការគ្រប់គ្រងរួមគ្នាលើធនធាននៅក្នុងសហគមន៍នេសាទ គឺជាឱកាសមួយ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន ជាពិសេស ដោយពិចារណាអំពីកាបូនខៀវ និងការរួមចំណែកថ្នាក់ជាតិក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (NDC) របស់កម្ពុជា ។ ផ្អែកតាមចំណុចដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាមធ្យមប្រចាំឆ្នាំចំនួន 21.54 MtCO2e/ឆ្នាំ សម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត ការដាំព្រៃកោងកាងឡើងវិញ និងការបញ្ចៀសការបំផ្លាញព្រៃកោងកាង និងស្មៅសមុទ្រ ក្រោមអាណត្តិរបស់សហគមន៍នេសាទរឹងមាំ អាចរួមចំណែកសម្រេចចំណុចដៅនេះ។ ឧទាហរណ៍ មានការប៉ាន់

ប្រមាណថា ការពង្រឹងអាណាត្តិរបស់សហគមន៍នេសាទកោះគ្រឹះស្នាលក និងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ (សហគមន៍នេសាទនៅតំបន់ឆ្នេរ ៨ លើ ៤១ នៅកម្ពុជា ត្រឹមឆ្នាំ ២០២៤) អាចរួមចំណែកប្រមាណ ០,២២% នៃចំណុចដៅប្រចាំឆ្នាំ សម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត។ កិច្ចខិតខំប្រឹងប្រែងអភិរក្ស និងស្តារឡើងវិញប្រកបដោយប្រសិទ្ធភាព ក្រោមការសម្របសម្រួលលើអាណិត្តរបស់សហគមន៍នេសាទដែលមានភាពរឹងមាំ និងការរៀបចំការគ្រប់គ្រងរួមគ្នាក្នុងសហគមន៍នេសាទនៅតំបន់ឆ្នេរទាំង ៤១ អាចក្លាយជាគំរូសម្រាប់បំពេញបន្ថែមលើការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចលើកឡើងក្នុង NDC។ សរុបមក នេះជាអនុសាសន៍សំរាប់ពិចារណាលើការរួមចំណែកដល់វិស័យជលផលនៅកម្ពុជា (ព្រៃកោងកាង ស្មៅសមុទ្រ ព្រៃលិចទឹក និងតំបន់អភិរក្សជលផល) ជាពិសេសនៅក្នុងបរិបទការរួមចំណែកថ្នាក់ជាតិក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (NDC) នៅឆ្នាំបន្ទាប់២០២៥[22]។ វិធីសាស្ត្រនេះនឹងគាំទ្រដល់គោលដៅកាត់បន្ថយ(ការប្រែប្រួលអាកាសធាតុ) ប្រកបដោយមហិច្ឆតារបស់ប្រទេសកម្ពុជា សម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត (FOLU) ។

[22] សូមពិនិត្យមើលឯកសារ 'កាបូនខៀវ និងការរួមចំណែកថ្នាក់ជាតិក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ - គោលការណ៍ណែនាំស្តីពីសកម្មភាពលើកកម្ពស់ (២០២៣) (Blue Carbon and Nationally Determined Contributions – Guidelines on Enhanced Action (២០២៣)') សម្រាប់គោលការណ៍ណែនាំដែលបានស្នើឡើងអំពីរបៀបដាក់បញ្ចូលកាបូនខៀវទៅក្នុង NDC ដោយពិចារណាលើវដ្តនៃការធ្វើបច្ចុប្បន្នភាព NDC ចាប់ពីឆ្នាំ២០២៥ តទៅ។

# ឯកសារយោង


ADB. (2022). *Cambodia: Sustainable Coastal and Marine Fisheries Project.* -: Asian Development Bank.

ArcGIS. (2021, April 3). *Mapping Mangroves in Cambodia*. Retrieved from Evaluating mangrove forest land cover changes in Kampong Som Bay, Cambodia: https://storymaps.arcgis.com/stories/7949763f7c804cc88100d4237badd777

Arifanti, V., Sidik, F., & et al. (2022). *Challenges and Strategies for Sustaianble Mangrove Management in Indonesia.* -: Forests.

Bijeesh, K., & Ngo, X. (2019). *Mangrove forests of Cambodia: Recent changes and future threats.* -: Ocean & Coastal Management (Volume 181).

FAO. (2017). *Community Fisheries Organizations of Cambodia.* Food and Agriculture Organization of the United Nations.

FAO. (2024). *EARTH MAP*. Retrieved from Cambodia: https://earthmap.org/

FAO. (2024). *Food and Agriculture Organization of the United Nations*. Retrieved from Economic and Policy Analysis of Climate Change - The EX-Ante Carbon-balance Tool (EX-ACT): https://www.fao.org/in-action/epic/ex-act-tool/suite-of-tools/ex-act/en/

FAO. (2024). *GAEZ Data Portal*. Retrieved from Harmonized World Soils Database: https://gaez.fao.org/pages/hwsd

Friess, D., Thompson, B., & et al. (2016). *Policy challenges and approaches for the conservation of mangrove forests in Southeast Asia.* -: Conservation Biology, 933-949.

GMW. (2024). *Global Mangrove Watch*. Retrieved from Cambodia: https://www.globalmangrovewatch.org/country/KHM

KoC. (2020). *Cambodia's Updated Nationally Determined Contribution.* Kingdom of Cambodia.

Landesa. (2023). *Assessment for Pilot Site Selection and Project Recommendations.*

Mcleod, E., & et al. (2011). *A blueprint for blue carbon: toward an improved understanding of the role of vegetated coastal habitats in sequestering CO2.* Front. Ecol. Environ.

Sharma, S., & et al. (2020). The impacts of degradation, deforestation and restoration on mangrove ecosystem carbon stocks across Cambodia. *Science of the Total Environment*, 706.

TNC. (2024). *The Nature Conservancy*. Retrieved from Blue Carbon: https://www.nature.org/

Landesa

# ឧបសម្ព័ន្ធទី១

**តារាងទី 1.** ស្តុកកាបូននៅក្នុងសមាសជាតុនៃប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងក្នុងប្រទេសកម្ពុជា (ឆ្នាំ ២០២០)

| តំបន់ | ការប្រើប្រាស់ដី ប្រភេទគម្របដី | ស្តុកកាបូននៅក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងៗ (Mg Cha[1]) | | | | |
|---|---|---|---|---|---|---|
| | | ដើមឈើ | ឈើធ្លាក់ចុះ | ឫស | ដី | ប្រព័ន្ធអេកូសរុប |
| ខាងត្បូងនៃប្រទេសកម្ពុជា | Mean + SE | 51.3 ± 6.9 | 13.0 ± 2.3 | 35.4 ± 3.7 | 840.1 ± 31.9 | 957.2 ± 32.8 |
| កណ្តាលនៃប្រទេសកម្ពុជា | Mean + SE | 44.3 ± 10.5 | 7.0 ± 1.7 | 22.3 ± 5.5 | 481.6 ± 30.9 | 628.9 ± 33.1 |
| ខាងជើងនៃប្រទេសកម្ពុជា | Mean + SE | 20.5 ± 5.8 | 12.1 ± 6.0 | 16.0 ± 4.3 | 302.9 ± 17.1 | 386.2 ± 19.1 |
| កម្ពុជា | Pristine + SE | 65.6 ± 9.3 | 14.4 ± 2.4 | 40.6 ± 17.7 | 688.5 ± 49.9 | 809.2 ± 52.8 |
| | Degraded + SE | 61.9 ± 9.3 | 20.2 ± 5.3 | 42.1 ± 19.0 | 497.4 ± 81.1 | 621.7 ± 89.3 |
| | Deforested + SE | 0 | 0 | 0 | 326.7 ± 45.3 | 326.7 ± 45.3 |

ប្រភព៖ ដកស្រង់ចេញពី Sharma & et al. (2020)